# កិច្ចព្រមព្រៀងពាណិជ្ជកម្ម

# រវាង

# រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាល នៃសាធារណរដ្ឋកូរ៉េ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិង រដ្ឋាភិបាល នៃ សាធារណរដ្ឋកូរ៉េ (ដែលបន្ទាប់ទៅនេះហៅកាត់ថា " ភាគីហត្ថលេខី " ) ។

ក្នុងគោលបំណង ពង្រឹងពង្រីកទំនាក់ទំនងពាណិជ្ជកម្ម រវាង ប្រទេសទាំងពីរ ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ ស្មើភាព និង មានផលប្រយោជន៍ទៅវិញទៅមក និង ឈរលើមូលដ្ឋាន នៃលក្ខខ័ណ្ឌប្រជាជាតិ ទទួលការអនុគ្រោះបំផុត ដើម្បី បង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ភាគីទាំងពីរ បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ :

## មាត្រា ១

តាមក្របខ័ណ្ឌនៃច្បាប់ និង បទបញ្ញត្តិនៃប្រទេសទាំងពីរ ភាគីទាំងពីរ នឹង ត្រូវចាត់គ្រប់វិធានការណ៍សមស្របដើម្បីសំរួល ពង្រឹងពង្រីក និង បង្កើនពហុភាពនៃពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ លើមូលដ្ឋានស្មេរភាព និង យូរអង្វែង ។

## មាត្រា ២

ភាគីហត្ថលេខី ត្រូវយល់ព្រមជូនគ្នាទៅវិញទៅមក នូវ លក្ខខ័ណ្ឌជាប្រជាជាតិអនុគ្រោះបំផុត ចំពោះគ្រប់បញ្ហាទាក់ទងដល់ វិស័យពាណិជ្ជកម្ម ជាពិសេសចំពោះ :

**(ក)** ពន្ធគយ និង កំរៃផ្សេងៗគ្រប់ប្រភេទដែលអនុវត្តចំពោះ ការនាំចូល-នាំចេញ នាំចេញបន្ត ឬ ទំនិញឆ្លងកាត់ដើម្បី នាំចេញទៅកាន់ប្រទេសទី ៣ រួមទាំងបទបញ្ញត្តិ នីតិវិធី និង បែបបទ នៃ ការប្រមូលពន្ធ និង កំរៃផ្សេងៗ

**(ខ)** វិធីសាស្ត្រនៃការទូទាត់ សំរាប់ការនាំចូល- នាំចេញ រួមទាំងបែបបទផ្ទេរជាលក្ខណះ អន្តរជាតិ នៃ ការទូទាត់ ទាំងនោះផង

**(គ)** បទបញ្ញត្តិ នីតិវិធី និងបែបបទ ដែលទាក់ទងដល់ការនាំចូល- នាំចេញ រួមទាំងការធ្វើ បែបបទគយ បែបបទឆ្លងកាត់ ការស្តុកឃ្លាំង និង បែបបទនៃការផ្ទេរទំនិញ ដែលនាំចូល ឬ នាំចេញ

**(ឃ)** ពន្ធនានា និង កំរៃក្នុងស្រុកដទៃទៀត ដែលមានទំនាក់ទំនង ដោយផ្ទាល់ ឬដោយ ប្រយោល ចំពោះ ទំនិញនាំចូល និង

**(ង)** បទបញ្ញត្តិដែលទាក់ទងដល់ ការលក់-ទិញ ដឹកជញ្ជូន បែងចែក ស្តុកទំនិញ និងការ ប្រើប្រាស់ទំនិញ នៅក្នុងទីផ្សារក្នុងស្រុក

## មាត្រា ៣

ប្រការទាំងឡាយ នៃមាត្រា ២ នឹង មិនត្រូវបានលើកយកមកអនុវត្តទេ ចំពោះ :

**(ក)** ភាពអនុគ្រោះ និង ផលប្រយោជន៍ទាំងឡាយ ដែលភាគីហត្ថលេខីណាមួយ បានផ្តល់ ឬ អាចនឹង ផ្តល់ទៅឱ្យប្រទេសជិតខាង ដើម្បីសំរួលនូវពាណិជ្ជកម្មតាមព្រំដែន និង

**(ខ)** ការផ្តល់ ភាពអនុគ្រោះពិសេស ដែលកើតឡើងពីការចូលរួមក្នុង សហភាពគយ ឬ តំបន់ពាណិជ្ជកម្មសេរីណាមួយ ឬក្រុមសេដ្ឋកិច្ចតំបន់ ដែលភាគីណាមួយនៃភាគីហត្ថលេខី ជាសមាជិកឬ អាចនឹងក្លាយជាសមាជិកក្នុងពេលអនាគត ។

## មាត្រា ៤

យោងតាមច្បាប់ និង បទបញ្ញត្តិទាំងឡាយ របស់ប្រទេសទាំងពីរ ភាគីចុះហត្ថលេខី នឹងធ្វើការ លើកលែង ពន្ធគយ ពន្ធដារ និង កំរៃផ្សេងៗលើមុខទំនិញមួយចំនួនដូចខាងក្រោម នៅពេលដែលមុខទំនិញ ទាំងនោះធ្វើការនាំចូល-នាំចេញ :

**(ក)** ទំនិញគំរូគ្រប់ប្រភេទប្រសិនបើទំនិញទាំងនោះគ្មានតំលៃពាណិជ្ជកម្ម និងគ្មានបំណងដាក់លក់

**(ខ)** ទំនិញ និង សំភារៈទាំងឡាយដែលនាំចូល សំរាប់កែឆ្នៃ និង ជួសជុល ប្រសិនបើទំនិញ និង សំភារៈទាំងនោះ នឹង ត្រូវបានធ្វើការនាំចេញទៅវិញ

**(គ)** វត្ថុទាំងឡាយ សំរាប់ធ្វើការពិសោធន៍ និង សាកល្បង

**(ឃ)** ទំនិញដែលត្រូវដាក់តាំងនៅក្នុងពិពណ៌ និងការតាំងបង្ហាញនានា ប្រសិនបើទំនិញទាំងនោះ នឹងត្រូវ បាននាំចេញទៅវិញ

(ខ) បណ្តាកុងទែន័រឯកទេស និង សំភារៈវេចខ្ចប់នានា ដែលប្រើប្រាស់ ក្នុងវិស័យពាណិជ្ជកម្ម អន្តរជាតិ ប្រសិនបើ កុងទែន័រ និង សំភារៈទាំងនោះ នឹងត្រូវបាននាំចេញទៅវិញ

(ឃ) ឧបករណ៍ និង សំភារៈឯកទេស ដែលត្រូវបានប្រើប្រាស់ ក្នុងសំណង់ និង ការតម្លើងផ្នែក ឧស្សាហកម្មផ្សេងទៀតហើយដែលឧបករណ៍ទាំងនោះពុំអាចរកបាននៅក្នុងស្រុក ហើយត្រូវ នាំចូលដោយក្រុមហ៊ុន ឬ ដោយនីតិបុគ្គលនៃប្រទេសដទៃ ដែលទទួលបន្ទុកអនុវត្តការ សាងសង់ បើឧបករណ៍ និង សំភារៈទាំងនោះ នឹងត្រូវបាននាំចេញទៅវិញ ក្នុងអំឡុងពេល កំណត់ណាមួយ ។

## មាត្រា ៥

រាល់ការទូទាត់ដែលធ្វើឡើងក្រោមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ នឹងបានត្រូវអនុវត្តក្រោមរូបភាព រូបិយវត្ថុ អាចផ្ទេរបាន ដោយសេរី ដោយយោងតាមបទបញ្ញត្តិ ជាធរមាន នៃប្រទេស ទាំងពីរ ។

## មាត្រា ៦

អនុលោមតាមច្បាប់ និង បទបញ្ញត្តិរបស់ខ្លួន ភាគីហត្ថលេខីនិមួយៗ នឹង ផ្តល់ជូនដល់ រូបវ័ន្តបុគ្គល នៃ ប្រទេសមួយទៀត ដោយផ្អែកតាមប្រការទាំងឡាយ នៃកិច្ចព្រមព្រៀងនេះ នូវរាល់ការ ជួយឧបត្ថម្ភ គាំទ្រចាំបាច់ដើម្បីសំរួលការងាររបស់ពួកគេ និងធានានូវការបំពេញភារកិច្ចរបស់ពួកគេ ឱ្យបានជោគជ័យ ។

## មាត្រា ៧

ផ្អែកតាមសំណូមពរនៃភាគីហត្ថលេខីណាមួយ អ្នកតំណាងនៃភាគីហត្ថលេខីទាំងសងខាង នឹងធ្វើការ ពិភាក្សានូវរាល់វិធានការ សំដៅពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឬ ដោះស្រាយបញ្ហា ទាំងឡាយណា ដែលកើតឡើងដោយការអនុវត្តកិច្ចព្រមព្រៀងនេះ ក្នុងស្មារតីសហប្រតិបត្តិការ និង

យោគយល់គ្នាទៅវិញទៅមក ។ ប្រសិនបើចាំបាច់ ទីកន្លែង និង កាលបរិច្ឆេទនៃការពិភាក្សាទាំងនេះ នឹងត្រូវបានកំណត់ តាមការព្រមព្រៀងទៅវិញទៅមក ។

## មាត្រា ៨

១. កិច្ចព្រមព្រៀងនេះ មិនត្រូវហាមឃាត់ ភាគីហត្ថលេខីណាមួយ មិនឱ្យធ្វើការហាមឃាត់ ឬ ដាក់ កំហិតណាមួយ សំដៅការពារដោយផ្ទាល់នូវផលប្រយោជន៍ សន្តិសុខ ឬ សុខភាព សាធារណៈ ឬ ការការពាជំងឺឆ្លង និង ជំងឺប៉េស្ត ដែលមានចំពោះសត្វពាហនៈ ឬ ដំណាំ ។

២. ការហាមឃាត់ ឬ ការដាក់កំហិតទាំងនេះ មិនត្រូវបានយកមកប្រើប្រាស់ ជាមធ្យោបាយ នៃ ការរើសអើង មិនសមហេតុផល ឬការកំណត់ព្រំខ័ណ្ឌ មិនសមរម្យ ចំពោះពាណិជ្ជកម្ម រវាង ប្រទេសទាំងពីរឡើយ ។

## មាត្រា ៩

រាល់វិវាទទាំងឡាយណាដែលកើតឡើងពី ការបកស្រាយ ឬ អនុវត្តប្រការទាំងឡាយនៃ កិច្ចព្រមព្រៀងនេះ នឹងត្រូវបានដោះស្រាយដោយលក្ខណះមិត្តភាព រវាង ភាគីហត្ថលេខីទាំងសងខាង តាមរយៈបណ្តាញការទូតរបស់ខ្លួន ។

## មាត្រា ១០

១. កិច្ចព្រមព្រៀងនេះ នឹង ចូលជាធរមានក្នុងរយៈពេល ៣០ថ្ងៃ (សាមសិបថ្ងៃ) ក្រោយពី កាលបរិច្ឆេទ នៃការជូនដំណឹងជាចុងក្រោយ របស់ភាគីចុះហត្ថលេខីណាមួយចំពោះ

ភាគីហត្ថលេខីមួយទៀត ដែលការជូនដំណឹងនេះថែងថា រាល់លក្ខខ័ណ្ឌផ្លូវច្បាប់ទាំងអស់ ដើម្បីឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវ បានបំពេញរួចស្រេចហើយ ។

២. កិច្ចព្រមព្រៀងនេះនឹងស្ថិតជាធរមានក្នុងរយៈពេល**០៥ឆ្នាំ**( ប្រាំឆ្នាំ) ហើយត្រូវបានពន្យា ជាស្វ័យប្រវត្តិ សំរាប់រយៈពេល ០៥ឆ្នាំ ជាបន្តបន្ទាប់ទៀត លើកលែងតែភាគីណាមួយ ជូនដំណឹងភាគីម្ខាងទៀត ជាលាយលក្ខ័អក្សរ អំពីចេតនារបស់ខ្លួនចង់បញ្ចប់កិច្ចព្រមព្រៀង នេះ នៅក្នុង រយៈពេល **៩០ ថ្ងៃ** ( កៅសិបថ្ងៃ) ជាមុន ។

៣. កិច្ចព្រមព្រៀងនេះអាចនឹងបានត្រូវធ្វើការកែប្រែ ដោយមានការយល់ព្រម ពីភាគីទាំងសង ខាង រាល់ការកែប្រែទាំងឡាយឬ ការបញ្ចប់កិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬកាតព្វកិច្ច ដែលកើតឡើង ឬ ទទួលបានតាមកិច្ចព្រមព្រៀងនេះទេ មុនពេលដែល កាលបរិច្ឆេទ ចូលជា ធរមាននៃការកែប្រែ ឬ ការបញ្ចប់នោះបានមកដល់ ។

## មាត្រា ១១

កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម និង ការទូទាត់រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋកូរ៉េ ដែលចុះហត្ថលេខានៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៦៤ និង ចូលជាធរមាននៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៦៤ ត្រូវបានគ្របដណ្តប់ដោយអានុភាពនៃកិច្ចព្រមព្រៀងនេះ ចាប់តាំងពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះ ចូលជាធរមាន។ កិច្ចព្រមព្រៀងនេះ នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬកាតព្វកិច្ចដែលទទួលបាន ឬ កើតឡើង តាមប្រការនានានៃកិច្ចព្រមព្រៀងពីមុន មុនពេលដែលកាលបរិច្ឆេទ ចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ បានមកដល់ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពីរដ្ឋាភិបាលរបស់ភាគីទាំងសងខាង បានចុះហត្ថលេខាខាងក្រោមលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើជា ០២ ច្បាប់ (ពីរច្បាប់) ដើម នៅរាជធានី ភ្នំពេញនា ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០០២ ជា ភាសា ខ្មែរ កូរ៉េ និង អង់គ្លេស ។ អត្ថបទទាំងអស់នៃកិច្ចព្រមព្រៀងនេះ មានតំលៃស្មើគ្នាជាគតិយុត្តិ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាគោល ។

**ជ. រាជរដ្ឋាភិបាល នៃ**
**ព្រះរាជាណាចក្រកម្ពុជា**

**ជ. រដ្ឋាភិបាល នៃ**
**សាធារណរដ្ឋ កូរ៉េ**

김항경